ថ្ងៃ៨ល្អ ខែ12 ឆ្នាំ2020
សមាគមGTS

# ជូនទៅកាន់កម្មសិក្សាការីទាំងអស់គ្នា

ខែកត្តិក(ខែ១២)ចូលមកដល់, កាន់តែរងាខ្លាំងឡើងហើយ។
តើសិស្សទាំងអស់គ្នា សុខសប្បាយជាទេ?
បច្ចុប្បន្នមេរោគកូរ៉ូណាថ្មីក៏បាននឹងកំពុងឆ្លងរីករាលដាលឡើង
សូមអនុវត្តន៍វិធានការណ៍នឹងបង្ការការពារទុកជាមុនឲ្យបានកុំអោយឆ្លងមេរោគនេះទៅកាន់អ្នកទាំងអស់គ្នា ហើយសូមប្រុងប្រយ័ត្នថែរក្សាសុខភាព ដើម្បីឆ្លង ឆ្នាំថ្មីដោយសុខសប្បាយជាមួយគ្នា។
បន្ថែមពីនេះទៀត នៅថ្ងៃសំរាកជាច្រើនថ្ងៃ ក៏មានការចំណាយច្រើនខ្ជះខ្ជាយទៅលើថាមពលអគ្គីសនីនៅកន្លែងស្នាក់នៅ ។
ដូច្នេះត្រូវយកចិត្តទុកដាក់ចំពោះការសន្សំសំចៃភ្លើងអគ្គីសនី
នៅពេលចេញទៅខាងក្រៅត្រូវប្រុងប្រយ័ត្នការភ្លេចបិទកុងតាក់ម៉ាស៊ីនកំដៅ។
សូមយកចិត្តទុកដាក់អោយបានម៉ត់ចត់នៅចំណុចគួរប្រុងប្រយ័ត្ននៅថ្ងៃសំរាកដើមឆ្នាំចុងឆ្នាំមានសង្ខេបដូចខាងក្រោម

ចំណាំ

**1.អំពីការការពារការឆ្លងមេរោគកូរ៉ូណាថ្មី**

・ពាក់ម៉ាស,ជៀសវាងការនិយាយជាមួយមនុស្សដោយមិនបានពាក់ម៉ាស
・រក្សាគម្លាតរវាងគ្នានឹងគ្នាចាប់ពី១ម៉ែតឡើងទៅ
・ជៀសវាងការជួបជុំទ្រង់ទ្រាយធំនិងពិធីជប់លៀងផឹកស៊ីរយះពេលយូរ
・បន្ទប់ពេលដែលមិនប្រើត្រូវបើបង្អួចអោយធំៗជាដើម,
ធ្វើឱ្យខ្យល់ចេញចូលទោះបីជាបរិយាកាសត្រជាក់ក៏ដោយ។

https://www.otit.go.jp/CoV2_jissyu_kansen/ ←សូមពិនិត្យនៅទីនេះ សំរាប់ការបញ្ជាក់បន្ថែម

**2.អំពីជំងឺ**

ការការពារជំងឺផ្តាសាយ ផ្តាសាយធំប្រភេទថ្មី
・ពេលត្រលប់មកពីខាងក្រៅ, មុនចំអិនអាហារដាច់ខាតត្រូវលាងដៃនិងខ្ពុរមាត់។
・ត្រូវរស់នៅដោយត្រឹមត្រូវទៅតាមច្បាប់○○៖(កុំនៅដល់យប់ជ្រៅពេក)
・ត្រូវយកចិត្តទុកដាក់ទៅលើរបបអាហារញុំាដែលផ្តល់ជីវជាតិគ្រប់គ្រាន់។

**3. អំពីគ្រោះថ្នាក់ចរាចរណ៍**

ត្រូវគោរពច្បាប់ចរាចរណ៍ប្រទេសជប៉ុនអោយបានខ្ជាប់ខ្ជួន ដើម្បីកុំអោយជួបគ្រោះថ្នាក់ចរាចរ
សិនបើមានគ្រោះថ្នាក់កើតឡើង
ទូរស័ព្ទដៃជាមួយនិងកាតស្នាក់នៅ និងកាតទំនាក់ទំនង, នៅពេលកើតស្ថានភាពមិនបានគ្រោងទុក ត្រូវរក្សាអារម្មណ៍ ហើយសូមទំនាក់ទំនងទៅអ្នកស្នាក់នៅជាមួយ និងសមាគម
លើសពីនេះ, ត្រូវគោរពច្បាប់ចរាចរពេលជិះកង់។ គោរពច្បាប់ចរាចរ គឺគោរពជីវិតខ្លួនឯង

## 4. អំពីការងារក្រៅម៉ោង

ការងារក្រៅម៉ោងនិងការងារធ្វើតាមផ្ទះ ត្រូវបានហាមឃាត់មិនឲ្យកម្មសិក្សាការីធ្វើនោះទេ! ថ្វីបើទទួលបានសិទ្ធស្នាក់នៅក៏ដោយ មានន័យថាអ្នកជាកម្មសិក្សាការីរីកហាត់ជំនាញគឺ "ការហ្វឹកហ្វឺនបច្ចេកទេសលេខ 1R" និង "ការហ្វឹកហ្វឺនបច្ចេកទេសលេខ 2 R"។ ការទទួលយកប្រាក់ឈ្នួលនៅតាមគ្រឹះស្ថាននិងហាងផ្សេងៗគឺជាសកម្មភាពខុសច្បាប់ ហើយនឹងបណ្តាលឲ្យក្រុមហ៊ុននិងសមាគមរបស់អ្នកត្រូវទទួលទោសផងដែល! លើសពីនេះទៅទៀតវាជាសកម្មភាពមួយខុសពីការហ្វឹកហ្វឺនជំនាញជាក់ស្តែង ហើយអ្នកនឹងត្រូវបញ្ជូនវិលត្រឡប់ទៅផ្ទះវិញ។

## 5. អំពីការរញ្ជួយដី

ប្រទេសជប៉ុនត្រូវបានគេដឹងថាជាប្រទេសដែលមានការរញ្ជួយដីជាច្រើន។ ប្រសិនបើមានការរញ្ជួយដីកើតមានឡើងតើអ្នកគួរធ្វើអ្វី? តើអ្នកទាំងអស់គ្នាដឹងដែរឬទេ? បន្ទាប់ពីអ្នកមើលសៀវភៅ ( http://www.fdma.go.jp/relocation/bousai_manual/index.html ) ស្តីពីសៀវភៅណែនាំអំពីការការពារគ្រោះមហន្តរាយរបស់ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយនិងទីភ្នាក់ងារអគ្គីភ័យ អ្នកនឹងទទួលបានទទួលចំណេះដ៏ល្អ។

## 6.ផ្សេងៗ

ដាច់ខាត់ត្រូវគោរពច្បាប់ក្រុមហ៊ុន ច្បាប់នៅកន្លែងស្នាក់នៅ និងច្បាប់របស់ប្រទេសជប៉ុន។ ឧក្រិដ្ឋជនត្រូវបានដាក់ទោសដោយមិនគិតពីជនជាតិជប៉ុនឬជនបរទេសឡើយ។ ប្រសិនបើអ្នកធ្លាប់ជាប់បទព្រហ្មទណ្ឌហើយ អ្នកនឹងមិនអាចលុបប្រវត្តិនោះបានទេ។

・ហាមឃាត់ការស្នាក់ខាងក្រៅដោយមិនមានការអនុញ្ញាត។ ចូរសុំច្បាប់ពីក្រុមហ៊ុន ឬសមាគមជាមុនសិន។

・គ្រូបង្រៀនណែនាំការរស់នៅអាចនឹងដើរត្រួតពិនិត្យកន្លែងស្នាក់នៅគ្រប់ពេល ! ប្រសិនបើមានបញ្ហា អ្នកត្រូវតែទាក់ទងទៅសមាគមផង។វានឹងមានការលំបាកស្នើសុំបច្ចុប្បន្នភាព VISA ទៅកាន់អន្តោប្រវេសន៍ ប្រសិនបើអ្នកត្រូវបានគេបញ្ជាក់ថាអាកប្បកិរិយាក្នុងការរស់នៅរបស់អ្នកមិនល្អ។ នេះជាច្បាប់ដើម្បីឲ្យអ្នកទាំងអស់គ្នានៅប្រទេសជប៉ុនដោយសុវត្ថិភាពតែប៉ុណ្ណោះ ! ដូចនេះហើយអ្នកត្រូវគោរពវិន័យ ហើយកុំសប្បាយមួយពេលដែលធ្វើឲ្យអ្នកខូចអនាគត !

## ការលួចទំនិញតាមហាង និងជិះកង់ដែលគេទុកចោលទាំងនេះគឺជាអំពើខុសច្បាប់ ដែលមិនអាចលើកលែងបាន !

ជាអកុសលមានការកើនឡើងចំនួនករណីឧក្រិដ្ឋកម្មដែលបង្ករដោយក្នុងពេលរីកហាត់ជំនាញ ! មិនត្រូវជឿពាក់លួងលោមសូម្បីតែជាជនជាតិដូចគ្នា។ពាក្យផ្អែមល្ហែមគឺជាអន្ទាក់។សូមជឿជាក់លើខ្លួនឯង !

## មិនត្រូវឲ្យលិខិតឆ្លងដែននិងប័ណ្ណស្នាក់ទៅកាន់នរណាម្នាក់ក្រៅពីសមាគម ឬក្រុមហ៊ុនទេ !

អ្នកនឹងមិនតម្រូវឲ្យស្មើរដោយផ្ទាល់ខ្លួននៅខាងអន្តោប្រវេសន៍ទេ។ជនខិលខូចតែងតែចង់បានលិខិតឆ្លងដែន ឬប័ណ្ណស្នាក់នៅរបស់អ្នក!

សូមប្រុងប្រយ័ត្ន!

ចប់